ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

លេខ........៥៦........ សកបយ

ភ្នំពេញ ថ្ងៃទី២០ ខែមិនា ឆ្នាំ ២០០១

# ប្រកាសរួម
## ស្តីពី
## អាករប័ណ្ណការងារនិងសៀវភៅការងារ

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
និង
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការងារ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម ០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញប្រកាសរួមលេខ ៣០២ សកអ / ៩៧ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧ របស់ក្រសួង សង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីពីអាករប័ណ្ណការងារ និង សៀវភៅការងារ

-បានឃើញការចាំបាច់របស់ក្រសួង

## សំ រេ ច

ប្រការ១ : កំណត់អាករប័ណ្ណការងារ និងសៀវភៅការងារដូចខាងក្រោម:

១. អាករសៀវភៅការងារកម្មករនិយោជិតខ្មែរ:

អាករសៀវភៅការងារនិយោជិតកម្មករខ្មែរម្នាក់ៗត្រូវបានកំណត់ចំនួន ១ ៥០០ រៀល ( មួយពាន់ប្រាំរយរៀលគត់ ) ។ អាករនេះត្រូវបានកំណត់ឱ្យបង់តែម្តងគត់ ។

២. អាករប្រចាំឆ្នាំនៃប័ណ្ណការងារ និងសៀវភៅការងារជនបរទេស:

ក. -អាករប្រចាំឆ្នាំប្រតិទិននៃសៀវភៅការងារ និងប័ណ្ណការងារជនបរទេសម្នាក់ៗ ដែលចូលមកស្នាក់នៅ ឬប្រកបមុខរបរអ្វីមួយ ឬធ្វើការអ្វីមួយយកប្រាក់ឈ្នួល មានរយៈពេលកំណត់ ត្រូវបានកំណត់ចំនួន ១០០ ដុល្លាអាមេរិក ( មួយរយដុល្លាអាមេរិក ) ។

ខ. -អាករប្រចាំឆ្នាំប្រតិទិននៃសៀវភៅការងារនិងប័ណ្ណការងារជនបរទេសម្នាក់ៗ ដែលរស់នៅអចិន្ត្រៃយ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ ត្រូវបានកំណត់ចំនួន ៥០ដុល្លាអាមេរិក ( ហាសិបដុល្លាអាមេរិក ) ។

ប្រការ ២ : សាមីជនបរទេសត្រូវបង់អាករនេះ ឱ្យបានមុនដំណាច់ខែមីនា ជារៀងរាល់ឆ្នាំ ចូលថវិកាជាតិ ដោយត្រូវមានចេញបង្កាន់ដៃទៅតាមច្បាប់ហិរញ្ញវត្ថុជូនដល់អ្នកបង់ ។

នៅរាជធានីភ្នំពេញ ផ្នែកបេឡាកណ្តាល នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវយកចំណូលនេះទៅបង់ជូនធនាគារជាតិ ។

ចំពោះនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនានា ចំណូលនេះត្រូវយកទៅបង់ជូនធនាគារ ខេត្ត ក្រុង រៀងៗខ្លួន ។

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានជុំនុំរបរ និងហត្ថពលកម្ម មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុង នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

និងប្រធានធនាគារជាតិ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៤: ជនដែលមិនបានបង់អាករ ទៅតាមការកំណត់ដូចខាងលើនេះ ត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៥ : ប្រកាសរួមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៣០២ សកអ/៩៧ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីអាករប័ណ្ណការងារ និងសៀវភៅការងារ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : ប្រកាសនេះមានសុពលភាពចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ

"ដើម្បីជ្រាប"

- ក្រសួងព័ត៌មាន "ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត ក្រុង

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ